**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ២៦៥ អនក្រ.បក .

# អនុក្រឹត្យ

**ស្តីពី**

**ការកាត់ដីសរុបទំហំ ៤.៦៩៨ ហិកតា ដែលក្នុងនោះ កាត់ចេញពីដី សម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាសូទីម ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវាទៀង ខេមបូឌា ពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ដូវាទៀងក្រចេះ ពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ច័ន្ទសុតា ព្រមទាំងស្នើសុំ ប្រទានកម្មជំនួសដីសម្បទានសង្គមកិច្ច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និងការផ្តល់សិទ្ធិលើក្បាលដី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧៩៨ ល.ក្រច ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៤.៦៩៨ ហិកតា ដែលក្នុងនោះ (១) ទំហំ ៧៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន កាសូទីម និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ៣.០១៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ខេមបូឌា (៣) ទំហំ ១២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ក្រចេះ (៤) ទំហំ ២២៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ច័ន្ទសុភា និង (៥) ធ្វើប្រទានកម្មទំហំ ១.៣៧១ ហិកតា ជំនួសដីសម្បទានសង្គមកិច្ច សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅឃុំដំរីផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដែលស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម៖

- ផ្ទៃដីទំហំ ៨០៣ ហិកតា ក្នុងនោះ (១) ទំហំ ៧៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន កាសូទីម និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ៧១៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ខេមបូឌា និង(៣) ទំហំ ១២ ហិកតា កាត់ចេញពីដី

សម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀង ក្រចេះ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិរំពុក ឃុំស្វាយជ្រះ

- ផ្ទៃដីទំហំ ៧៥៩ ហិកតា ក្នុងនោះ (១) ទំហំ ៧៣៦ ហិកតា ប្តូរពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ ៥៤ អនក្រ.បក និង (២)ទំហំ ២៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវ ទៀង ខេមបូឌា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិក្រូច ឃុំដំរីផុង
- ផ្ទៃដីសរុបទំហំ ៣.១៣៦ ហិកតា ក្នុងនោះ (១) ទំហំ ៦៣៥ ហិកតា ប្តូរពីដីសម្បទានសង្គមកិច្ចនៃអនុក្រឹត្យលេខ៥៤ អនក្រ.បក (២)ទំហំ ២២៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ច័ន្ទសុភា អភិវឌ្ឍន៍ (៣) ទំហំ ២.២៧៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ដូវទៀងខេមបូឌា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១.៦១៨ គ្រួសារ នៅឃុំដំរីផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដែលស្ថិតនៅក្នុងភូមិ ឃុំ ដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ១៩៨ គ្រួសារ នៅភូមិរំពុក ឃុំស្វាយជ្រះ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៤២ គ្រួសារ នៅភូមិក្រូច ឃុំដំរីផុង
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.១៧៨ គ្រួសារ នៅភូមិប្រឡាយទ្រៀក ឃុំដំរីផុង

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន លើក្បាលដីចំនួន ២.៣៣១ ក្បាលដី ជូនប្រជាពលរដ្ឋចំនួន ១.៦១៨ គ្រួសារ នៅឃុំដំរីផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដែលក្នុងនោះផ្តល់ជា ៖

- កម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៩៨ គ្រួសារ លើក្បាលដីចំនួន ២៤៥ ក្បាលដី នៅភូមិរំពុក
- កម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៤២ គ្រួសារ លើក្បាលដីចំនួន ២៩៤ ក្បាលដី នៅភូមិក្រូច

- កម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១.១៧៨ គ្រួសារ លើក្បាលដីចំនួន ១.៧៩២ ក្បាលដី នៅភូមិប្រឡាយទ្រៀក ។

**មាត្រា ៤ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តក្រចេះ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៥ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ៨ ឆ្នាំ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ១២

**ស្តីពីការកាត់ដីទំហំ ៩៥ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន CASOTIM**

**ស្ថិតនៅ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ**




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| | | | 10 | 627042 | 1357083 |
| 1 | 625501 | 1356829 | 11 | 627040 | 1356476 |
| 2 | 625722 | 1356951 | 12 | 626979 | 1356475 |
| 3 | 626061 | 1357058 | 13 | 626894 | 1356502 |
| 4 | 626246 | 1357067 | 14 | 626441 | 1356406 |
| 5 | 626413 | 1357071 | 15 | 626446 | 1356323 |
| 6 | 626608 | 1356975 | 16 | 625774 | 1356323 |
| 7 | 626630 | 1356924 | 17 | 625770 | 1356356 |
| 8 | 626829 | 1357025 | 18 | 625517 | 1356522 |

## ផែនទី បង្ហាញទីត..ដីទំហំ ៤៦៩៨ ហិកតា (បួនពាន់ប្រាំមួយរយកេ..ប់ប្រាំបី ហិកតា)

## ស្ថិតនៅ ឃុំជីផុច និង ឃុំស្វាយជ្រះ ស្រុកឆ្លូង និង ស្រុកស្នួល ខេត្តក្រចេះ



ផែនទី ក្រាញទីតាំងដីទំហំ ៩៥ ហិកតា (កៅសិបប្រាំ កតា)

ស្ថិតនៅ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 625501 | 1356829 | 10 | 627042 | 1357083 |
| 2 | 625722 | 1356951 | 11 | 627040 | 1356476 |
| 3 | 626061 | 1357058 | 12 | 626979 | 1356475 |
| 4 | 626246 | 1357067 | 13 | 626894 | 1356502 |
| 5 | 626413 | 1357071 | 14 | 626441 | 1356406 |
| 6 | 626608 | 1356975 | 15 | 626446 | 1356323 |
| 7 | 626630 | 1356924 | 16 | 625774 | 1356323 |
| 8 | 626829 | 1357025 | 17 | 625770 | 1356356 |
| 9 | 626869 | 1357051 | 18 | 625517 | 1356522 |
| | | | 19 | 625419 | 1356613 |